គង្គាតីរិយត្ថេរគាថា

គាថារបស់ព្រះគង្គាតីរិយត្ថេរមានពាក្យផ្តើមថា យើងធ្វើខ្ទមដោយស្នឹកត្នោត ៣ ធាង ។

សូរថា រឿងនេះកើតឡើងដូចម្តេច ?

ឆ្លើយថា បានឮមកថា ព្រះថេរៈនេះកើតក្នុងផ្ទះមានត្រកូល ក្នុងកាលនៃព្រះមានព្រះភាគព្រះនាម **បទុមុត្តរៈ** ។ កាលធំដឹងក្តីហើយ ជាអ្នកមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះសាសនា បានថ្វាយទឹកដល់ភិក្ខុសង្ឆ ។

ដោយបុញ្ញកម្មនោះ លោកបានទៅកើតក្នុងទេវលោក ហើយធ្វើបុណ្យជាបន្តបន្ទាន់ លោកត្រាច់រង្គាត់ទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ។ ក្នុងពុទ្ធុប្បាទនេះ លោកមកកើតជាបុត្រគហបតីម្នាក់ក្នុងក្រុងសាវត្ថី មានឈ្មោះថា **ទត្តៈ** ។ លោកចម្រើនវ័យធំហើយ នៅគ្រប់គ្រងផ្ទះ មិនដឹង**អគមនីយដ្ឋានភាព**[១] (ភាពជាវត្ថុដែលមិនគួរប្រព្រឹត្តកន្លង) បានប្រព្រឹត្តកន្លងល្មើស ខាងក្រោយមកលោកបានដឹង**អគមនីយដ្ឋានភាពនោះ** (ថាជាកំហុស) ទើបកើតសេចក្តីសង្វេគតក់ស្លុត ចេញបួស លោករង្ការសស្អប់ខ្ពើមក្នុងកម្ម(ជាទោសកំហុស)នោះ បានតម្កល់ខ្លួននៅក្នុង**ខ្ងលប្បដិបទា** (បដិបត្តិវត្តធ្វើខ្លួនសៅហ្មង គឺ) **ប្រើបង្សុកូលចីវរ, បាត្រដីមានលក្ខណៈស្រដៀងឆ្នាំងស្រោចទឹកខ្មោច**, និងធ្វើកុដិដោយស្លឹកត្នោត ៣ធាង នៅត្រង់មាត់ទន្លេគង្គា ព្រោះហេតុនោះ លោកទើបមានសមញ្ញានាមថា **គង្គាតីរិយៈ** ។

លោកអធិដ្ឋានចិត្តថា បើយើងមិនទាន់បានសម្រេចព្រះអរហត្តទេ នឹងមិនសន្ធនាជាមួយនរណាឡើយ លោកជាអ្នកស្ងៀមស្ងាត់អស់ឆ្នាំដំបូង នៅដោយមិននិយាយចរចា ។ ក្នុងឆ្នាំទី ២ ត្រូវស្ត្រីម្នាក់ក្នុងគោចរគ្រាម បំណងនឹងសាក

---

(១). **អគមនីយដ្ឋានភាព** ក្នុងទីនេះសំដៅដល់ រឿងរ៉ាវរបស់លោកដែលមិនស្គាល់ម្តាយនិងប្អូនស្រី ហើយយកធ្វើជាប្រពន្ធ (ចូរមើលសេចក្តីពិស្តារក្នុងគម្ពីរបរមត្ថទីបនី អដ្ឋកថាថេរីគាថា ទ្វាទសកនិបាត ឧប្បលវណ្ណាថេរីគាថាវណ្ណនា) ។

ល្បងមើលថា លោកជាមនុស្សគឬមិនមែន ។ នាងមុននឹងចាក់ទឹកដោះចូលក្នុងបាត្រ ក្លែងធ្វើជាពិការដៃ ហើយចាក់ចូល ។ ព្រះថេរៈក៏បញ្ចេញវាចាថា ល្មមហើយ ប្អូនស្រី ។ តែក្នុងឆ្នាំទី ៣ លោកព្យាយាមរហូតបានសម្រេចព្រះអរហត្ត ខាងក្នុងវស្សានោះឯង ។

សមដូចគាថាប្រព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បានថ្វាយទឹកមួយកួមចំពោះភិក្ខុសង្ឆដ៏ប្រសើរ នៃព្រះបទុមុត្តរសម្ពុទ្ធ ។

(ដោយកុសលកម្មនេះ) បើខ្ញុំចង់បានទឹកសម្រាប់ផឹក លើកំពូលភ្នំ លើចុងឈើ ក្នុងអាកាស ឬក្នុងផែន ដីក្នុងកាលណា ទឹកក៏កើតឡើងយ៉ាងឆាប់ដល់ខ្ញុំ ក្នុងកាលនោះ ។

ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឧទកទាន ។

កិលេសទាំងឡាយ ខ្ញុំដុត បំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។

ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ព្រះថេរៈពេលបានជាព្រះអរហន្តហើយ កាលនឹងព្យាករព្រះអរហត្ត ដោយ បំណងប្រាប់វត្តបដិបត្តិជាដំបូងរបស់ខ្លួន បានពោល ២ គាថាថា

តិណ្ណ្ហ មេ តាលបត្តានំ, ឧជ្ជាតីរេ ឧដី ឧតា;

ឆវសិត្ថោ មេ ឧត្ថោ, ឧំសុកូលញ្ច ចីវរំ។

ខ្ទមដែលខ្ញុំធ្វើទៀបច្នេរទន្លេគង្គា ដោយស្លឹកត្នោត ៣ ផង ក៏មានបាត្រ របស់ ខ្ញុំ ដូចជាឆ្នាំងស្រោចទឹដោះស្រស់ឆ្នា ក៏មានសំពត់បង្សុកូលក៏មាន ។

ទ្វិន្នំ អន្តរវស្សានំ, ឯកា វាចា មេ ភាសិតា;

ឥតិយេ អន្តរវស្សម្ហិ, ឥមោ ១ ច្ចោ ឧជ្ជាលិតោ។

ក្នុងរវាងពីរឆ្នាំ ខ្ញុំ និយាយវាចាតែ ១ មាត់ក្នុងរវាងឆ្នាំទី ៣ គំនរនៃងងឹត (អវិជ្ជា) ខ្ញុំក៏បានទម្លាយហើយ ។

ឧជ្ជាតីរិយត្ថេរគាថា ចប់ ៧

ដោយសជ្ឈាយ